ក

# មាតិកា

## I. ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


៣០-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/១០៣ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក គាន់ សុខជូ (KWON SUK JOO) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅ ខេត្តប៊ុសាន់ សាធារណរដ្ឋកូរ៉េ ១៤៤៩

៣០-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/១០៤ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក លីម មូនស៊ូ (LIM MOON SU) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅ ក្រុងភូសាន សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា លីម រិទ្ធី (LIM RITTHI) ១៤៥០

៣០-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/១០៨ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក យូន សេយ៉ុង (YOON SE YOUNG) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅ ក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ១៤៥១

៣០-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/១០៩ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក ឆា ដុងវន់ (CHA DONG WON) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅ ខេត្ត Gyoung-gi សាធារណរដ្ឋកូរ៉េ ១៤៥២

៣១-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/១៣០ ស្តីពីការតែងតាំងឯកឧត្តម ម៉ៅ សុចន្ថារា ជាទីប្រឹក្សា អគ្គលេខាធិការ ព្រឹទ្ធសភា មានឋានៈស្មើអនុរដ្ឋលេខាធិការ ១៤៥៣

១៧-០២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០២០៩/១៧៦ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក វ៉ង់ ឆឹងយី (WONG CHEONG YI) ជនជាតិចិន សញ្ជាតិចិន កើតនៅ ក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន ១៤៥៤

១៧-០២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០២០៩/១៧៨ ស្តីពីការតែងតាំងលោកជំទាវ ខែត តែមាលីស៊ីសួដា ជាឧត្តមប្រឹក្សាផ្ទាល់ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា បន្ថែមលើមុខងារបច្ចុប្បន្ន ១៤៥៥

១៧-០២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០២០៩/១៧៩ ស្តីពីការតែងតាំងលោកជំទាវ ខុំ សរសោទ៉ុត ជាឧត្តមប្រឹក្សាផ្ទាល់ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ១៤៥៦

២០-០២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០២០៩/១៨៣ ស្តីពីការតែងតាំងលោក **ទៅហ្វាយ ត្វយ** ជាឧកញ៉ា ១៤៥៧
២០-០២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០២០៩/១៨៤ ស្តីពីការប្រោសព្រះរាជទានទូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម.អស់លោក និងលោកស្រីចំនួន ៥៧ រូប ១៤៥៨
២០-០២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០២០៩/១៨៦ ស្តីពីការប្រោសព្រះរាជទានទូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ ឯកឧត្តម **ចម ប្រសិទ្ធ** ១៤៦០
២០-០២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០២០៩/១៨៧ ស្តីពីការប្រោសព្រះរាជទានទូវគ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម និងលោកជំទាវចំនួន ១២ រូប ១៤៦១
២០-០២-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០២០៩/១៨៨ ស្តីពីការផ្ទេរក្របខ័ណ្ឌឯកឧត្តម **សុត ផេង** ពីវរមន្ត្រីថ្នាក់លេខ ១០ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ទៅវរមន្ត្រីថ្នាក់លេខ ១០ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្តីការគណរដ្ឋមន្ត្រី ១៤៦២

## II. រាជរដ្ឋាភិបាល

### អនុក្រឹត្យ

០៣-៣-២០០៩ -អនុក្រឹត្យលេខ ៤៤ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ១៤៦៣
២៦-០២-២០០៩ -អនុក្រឹត្យលេខ ៣០១ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១៤៧០
០២-៣-២០០៩ -អនុក្រឹត្យលេខ ៣០២ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១៤៧២
០២-៣-២០០៩ -អនុក្រឹត្យលេខ ៣០៣ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១៤៧៤
០២-៣-២០០៩ -អនុក្រឹត្យលេខ ៣០៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៤៧៦
០២-៣-២០០៩ -អនុក្រឹត្យលេខ ៣០៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៤៧៧
០២-៣-២០០៩ -អនុក្រឹត្យលេខ ៣០៦ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១៤៧៨
០៣-៣-២០០៩ -អនុក្រឹត្យលេខ ៣០៧ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១៤៧៩
០៣-៣-២០០៩ -អនុក្រឹត្យលេខ ៣០៨ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិ ១៤៨៣
០៣-៣-២០០៩ -អនុក្រឹត្យលេខ ៣០៩ អនក្រ.តត ស្តីពីការតម្លើងថ្នាក់តាមសញ្ញាបត្រជូនមន្ត្រីរាជការ ១៤៨៤

០៣-៣-២០០៩ -អនុក្រឹត្យលេខ ៣១០ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១៤៨៥

០៣-៣-២០០៩ -អនុក្រឹត្យលេខ ៣១១ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១៤៨៧

០៣-៣-២០០៩ -អនុក្រឹត្យលេខ ៣១២ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១៤៩០


## III. ការងារបណ្តាក្រសួង

### ១. ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


២៤-០២-២០០៩ -ប្រកាសលេខ ១៩៦ សហវ.ប្រក.អពដ ស្តីពីការបែងចែកប្រាក់រង្វាន់ពីការត្រួតពិនិត្យពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ១៤៩១

២៧-០២-២០០៩ -ប្រកាសលេខ ២១១ សហវ.ប្រក ស្តីពីការបង្កើត និងកិច្ចដំណើការអង្គភាពគ្រប់គ្រងតម្លៃចម្លងការនៃទំនិញនាំចូល ១៤៩៣

២៧-០២-២០០៩ -ប្រកាសលេខ ២១២ សហវ.ប្រក ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ១៤៩៨


### ២. ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


០៥-៨-២០០៨ -លិខិតបញ្ជាក់លេខ ៤២១៣ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ីឡូាយដ៍ ផាតនើរ** ១៥០៨

០៥-៨-២០០៨ -លិខិតបញ្ជាក់លេខ ៤២១៤ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វិទើរ-ស៊ី ឡូជីស្ទិគ** ១៥១០

០៥-៨-២០០៨ -លិខិតបញ្ជាក់លេខ ៤២១៥ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គ្រែនខូន (ខេមបូឌា)** ១៥១២

០៥-៨-២០០៨ -លិខិតបញ្ជាក់លេខ ៤២១៦ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យ៉ា ហ្វាខ សប** ១៥១៤

០៥-៨-២០០៨ -លិខិតបញ្ជាក់លេខ ៤២១៧ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សុខា រតន: ឌីវេឡុបមេន អ៊ីមផត អិចផត** ១៥១៦

០៤-៨-២០០៨ -លិខិតបញ្ជាក់លេខ ៤២១៨ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡែនម៉ាគ ប្រតីធី ខនសាល់ធេន ខូ អិលធីឌី** ១៥១៨

០៥-៨-២០០៨ -លិខិតបញ្ជាក់លេខ ៤២១៩ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ថៅវ៉ូ (ខេមបូឌា) អ៊ីន** ១៥២០

០៥-៨-២០០៨ -លិខិតបញ្ជាក់លេខ ៤២២៣ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមបូ ស្ទីត** ១៥២២

០៦-៨-២០០៨ -លិខិតបញ្ជាក់លេខ ៤២២៧ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខីឆ្វ ប្រីហ្វេសិនណល** ១៥២៤

០៦-៨-២០០៨ -លិខិតបញ្ជាក់លេខ ៤២២៨ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្គ្រីន ហារវេស គ្រុប យូនៀន** ១៥២៦

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/១០៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ /១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក គាន់ សុខជូ (KWON SUK JOO) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៦៤ នៅខេត្តប៊ុសាន់ សាធារណរដ្ឋកូរ៉េ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៩៧.០៩០១.១០៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩

លេខ : ៩៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែ កុម្ភៈ ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/១០៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លីម មូនស៊ូ** (LIM MOON SU) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៥៥ នៅក្រុងកូសាន សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **លីម រិទ្ធី** (LIM RITTHI) ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*៣១៧.០៩០១.១០៧*

លេខ : ៩១៩ ច.ល

**ដើម្បីចម្លងចែក**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩* រាជធានីភ្នំពេញ,ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០០៩

**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/១០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ /១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក យូន សេយ៉ុង (YOON SE YOUNG) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៥៧ នៅក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចរល.០៩០១.១១១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩

លេខ : ៩៦ ច.ល
ជូនចំពោះ ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

យ៉ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/១០៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ /១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ឆា ឌុងវ៉ន់ (CHA DONG WON) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ១៩៧៥ នៅខេត្ត Gyoung-gi សាធារណរដ្ឋកូរ៉េ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៩០១.១១២

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩*

លេខ : ៩៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊ុន ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/១៣០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងឯកឧត្តម ម៉ៅ សុចន្ថារ៉ា ជាទីប្រឹក្សាអគ្គលេខាធិការ ព្រឹទ្ធសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា២** : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

១៥៧.០១០៩.១៣៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៩

លេខ [illegible] .ច.ល
[illegible]ចម្លងចែក
រាជធានីភ្នំពេញ.ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៩
[illegible]រាជរដ្ឋាភិបាល
[illegible]

# ព្រះរាជក្រឹត្យ

នស/រកត/០២០៩/១៧៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **វ៉ង់ ឈឹងយី** ( WONG CHEONG YI ) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ១៩៦៦ នៅក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

*ព.ស. ០៩០២. ១៧៩*

**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

លេខ : ១៦៨ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០០៩
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

ឃួន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០២០៩/១៧៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**តែងតាំង**

**លោកជំទាវ ខែត កែមាលី ស៊ីសូដា**

**ជា**

**ឧត្តមប្រឹក្សាផ្ទាល់**

**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

**បន្ថែមលើមុខងារបច្ចុប្បន្ន**

នរោត្តម សីហមុនី

៣៣.០៩០២.១៩១

**បានប្រថាប់ព្រះរាជលញ្ជករហើយ**

*ធ្វើនៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩*

បាន[illegible]តាមច្បាប់ដើម

ROYAUME DU CAMBODGE

លេខ ...០០៧... រ.ចច

រាជធានីភ្នំពេញ, ថ្ងៃទី ...[illegible]... ខែ ...[illegible]... ឆ្នាំ ២០០៩

សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ព្រះបរមរាជវាំង

MINISTÈRE DU PALAIS

គង់ សំអុល

# ព្រះរាជក្រឹត្យ

នស/រកត/០២០៩/១៧៥

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## តែងតាំង

លោកជំទាវ ជុំ សរសោភារ៉ត

ជា

ឧត្តមប្រឹក្សាផ្ទាល់
ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

នរោត្តម សីហមុនី

៣រល.០៩០២.១៩២

**បានប្រថាប់ព្រះរាជលញ្ឆករហើយ**

*ធ្វើនៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩*

**បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម**
លេខ ... [illegible] ... ព.រ.ល
រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩
[illegible] អធិបតីស្រីង្គារ
[illegible] រដ្ឋមន្ត្រីព្រះបរមរាជវាំង

គង់ សំអុល

# ព្រះរាជក្រឹត្យ

យើង

នស/រកត/០២០៩/១៩៣

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

លោក ចៅហ្វាយ ត្នុយ

ជា

ឧកញ៉ា

*ធ្វើនៅរាជធានីភ្នំពេញ. ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩*

ភ្ជាប់ព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់

៣៧.០៩០២.១៩៦

ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

លេខ : ៧៩៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ចិនកេង

# ព្រះរាជក្រឹត្យ

នស/រកត/០២០៩/១៩៨

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក‑ គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :

| | | | | | |
|---|---|---|---|---|---|
| ១ | ឯកឧត្តម | ប៊ុន ហ៊ាន | ២ | ឯកឧត្តម | ស៊ិន ទុន្នី |

ខ‑ គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :

| | | | | | |
|---|---|---|---|---|---|
| ១ | ឯកឧត្តម | ផង់ សារ៉េត | ២០ | លោក | ចាន់ ស៊ីណាត |
| ២ | ឯកឧត្តម | តន់ ម៉ាន់ផារ៉ា | ២១ | លោក | ជួន វណ្ណារិទ្ធ |
| ៣ | ឯកឧត្តម | មួង សេរ៉ីខន | ២២ | លោក | ផាំង វិយុទ្ធជា |
| ៤ | ឯកឧត្តម | លី ចារណា | ២៣ | លោក | ជុន ប៉េងឡុង |
| ៥ | ឯកឧត្តម | ណី លន់ | ២៤ | លោក | អ៊ុម វិបុល |
| ៦ | ឯកឧត្តម | តែ ឡីគឹម | ២៥ | លោក | ហេង វត្តម៉ូនីជា |
| ៧ | ឯកឧត្តម | ឯម ប៊ុនធឿន | ២៦ | លោក | ជាតិ ស៊ីទុត្ថា |
| ៨ | ឯកឧត្តម | ឡុង ខុង | ២៧ | លោក | ទួន គ្រឹះស្នា |
| ៩ | លោក | ចាន់ យុត្ថា | ២៨ | លោក | យឹម ប៊ុនរ៉ុម |
| ១០ | លោក | ម៉ី លីហ្វត | ២៩ | លោក | យិន ញ៉ាណា |
| ១១ | លោក | ប៉ិញ សច្ចុះ | ៣០ | លោក | ជោក ប៊ុនផុន |
| ១២ | លោក | ជួន ប៊ិតផុល | ៣១ | លោក | ឡុង ផលគុណ |
| ១៣ | លោក | ជា ឈុនគៀត | ៣២ | លោក | កែវ ច័យ |
| ១៤ | លោក | ជង សេងអ៊ឹម | ៣៣ | លោក | អៀ ពិសិដ្ឋ |
| ១៥ | លោក | ថេង តារា | ៣៤ | លោក | ខាន់ ចន |
| ១៦ | លោក | ម៉ៅ ហាក់ | ៣៥ | លោក | គឹម សាខុន |
| ១៧ | លោក | ឡឹង សុធាច័ន្ទនី | ៣៦ | លោក | ប៊ុន ហូ |
| ១៨ | លោក | លឹម វីរៈគ្រូ | ៣៧ | លោក | ហៀង ម៉េង |
| ១៩ | លោក | ពេជ្រ ទាសនា | | | |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

គ-គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :

| | | | | | |
|---|---|---|---|---|---|
| ១ | លោក | ឡុង សារ៉ាឌុជ | ៨ | លោក | ជី សុម៉ាលី |
| ២ | លោក | ស៊ុខ មុនីរតនា | ៩ | លោក | សង់ ទិសាល |
| ៣ | លោក | ឃ្លោក សំអេង | ១០ | លោក | ហ៊ុន សុច្ចរា |
| ៤ | លោក | សៅ សម្ផស្ស | ១១ | លោក | អៀង ចាន់តារ៉ា |
| ៥ | លោក | មុយ មុនិន្ទ | ១២ | លោក | សាញ់ មុនីរត្ន |
| ៦ | លោក | លឹម ផេង | ១៣ | លោក | ចាន់ វណ្ណា |
| ៧ | លោក | ស្វាយ សុគន្ធី | | | |

ឃ-គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ :

| | | | | | |
|---|---|---|---|---|---|
| ១ | ឯកឧត្តម | យិន ខួនកុះលនីន | ៤ | លោកស្រី | សិទ្ធ វណ្ណារ៉េត |
| ២ | ឯកឧត្តម | អ៊ិន ទិធុះ | ៥ | លោក | ស៊ឹង សុផល |
| ៣ | លោក | ឈោ ម៉ុនរិទ្ធ | | | |

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩*

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសព្ទាប់**

៣៩៧.០៩០២.១៩៧

**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

លេខ : ៤០៣ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ២០០៩

**អគ្គលេខាធិការគណៈរដ្ឋាភិបាល**

**ស៊ុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០២០៩/១៩៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាគូបការ

ចំពោះ

ឯកឧត្តម ចម ប្រសិទ្ធ

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩*

ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

*៣រល.០៩០២.១៩៩*

លេខ ១៩៥ ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០២០៩/១៩៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ទូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :-

ឯកឧត្តម គីម ស៊ីនថន

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :-

១-ឯកឧត្តម ឡិត ប៉ុង ៣-ឯកឧត្តម កែវ សុខណៃ

២-ឯកឧត្តម ឆាន់ សូរសំភ្លី ៤-ឯកឧត្តម តាន់ ស៊ុនតូ

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :-

១-ឯកឧត្តម ច័ន្ទ នរ៉ា ៤-ឯកឧត្តម ម៉ៅ ថូរ៉ា

២-ឯកឧត្តម ទ៊ា ជាង ៥-ឯកឧត្តម សុខ រុន

៣-ឯកឧត្តម ទើង សុធី

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ :-

១-ឯកឧត្តម ឈួន ជារ៉ា ៣-ឯកឧត្តម កាន ច័ន្ទមេត្តា

២-លោកជំទាវ តឹកវ៉ែត កំរេង

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩*

ឡកព្រះបរមនាម និងតាមព្រះរាជគ្រាសបង្គាប់

ប្រមុខរដ្ឋស្តីទី
ប្រធានព្រឹទ្ធសភា
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៣៧៧.០៩០២.១៩០

លេខៈ ២០០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឃុន ឋិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០២០៩/១៧៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានផ្ទេរក្របខ័ណ្ឌឯកឧត្តម **សុក ផេង** ពីវរមន្ត្រីថ្នាក់លេខ ១០ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ទៅវរមន្ត្រីថ្នាក់លេខ ១០ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

៣៧.០៩០២.១៩១

**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

លេខ : ១៩៧ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ មីនា ឆ្នាំ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

ស៊ុន ជិនភេន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៤.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

* * * * * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៩/១៧៣ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសេដ្ឋកិច្ច

សង្គមកិច្ច និងវប្បធម៌ ហៅកាត់ថា "អគ្គលេខាធិការដ្ឋាន ក.ស.វ." ដែលជាសេនាធិការសម្រាប់កិច្ចដំណើរការការងារប្រចាំថ្ងៃរបស់ ក.ស.វ. ។

## ជំពូកទី២

## មុខងារនិងភារកិច្ច

**មាត្រា ២.-**

អគ្គលេខាធិការដ្ឋាន ក.ស.វ. មានមុខងារនិងភារកិច្ចដូចតទៅ ៖

- បំពេញការងារផ្នែករដ្ឋបាល ផ្គត់ផ្គង់ និងបច្ចេកទេស ក្នុងកិច្ចដំណើរការរបស់ ក.ស.វ. ប្រកបដោយប្រសិទ្ធភាព
- រៀបចំរាល់កិច្ចប្រជុំនានារបស់ ក.ស.វ. ដោយផ្ទាល់ឬដោយសហការជាមួយអគ្គលេខាធិការរាជរដ្ឋាភិបាល
- រៀបចំផែនការបណ្តុះបណ្តាលនានា សម្រាប់ពង្រឹងនិងបង្កើនសមត្ថភាពរបស់មន្ត្រីនៃអគ្គលេខាធិការដ្ឋាន ក.ស.វ.
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ ក.ស.វ. ដាក់ជូន ក.ស.វ. ដើម្បីពិនិត្យនិងសម្រេច
- ប្រមូលទិន្នន័យនិងព័ត៌មានសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធជូន ក.ស.វ. សម្រាប់ធ្វើការវិភាគ ក្នុងដំណើរការពិនិត្យតាមដានស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ និងប្រចាំឆ្នាំ
- ជួយ ក.ស.វ. ក្នុងដំណើរការសិក្សាស្រាវជ្រាវលើប្រធានបទដែលជាបញ្ហាប្រឈមសំខាន់ៗ ពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- រៀបចំក្រុមការងារសម្រាប់ធ្វើការសិក្សា ស្រាវជ្រាវ និងចុះធ្វើអង្កេត លើប្រធានបទដែល ក.ស.វ. បានកំណត់ឱ្យ តាមកាលបរិច្ឆេទនិងរយៈពេលច្បាស់លាស់
- ជួយ ក.ស.វ. ក្នុងការព្យាករស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលអាចកើតមានឡើងនាពេលអនាគត
- រៀបចំឯកសារយោងនិងពាក់ព័ន្ធសម្រាប់កិច្ចប្រជុំរបស់ ក.ស.វ. ក្នុងដំណើរការពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តនានា ដែលបណ្តាក្រសួង ស្ថាប័នដាក់ស្នើមកទីស្តីការគណៈរដ្ឋមន្ត្រី
- រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យនិងព័ត៌មានសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ រួមទាំងឯកសារលិខិតបទដ្ឋានគតិយុត្តជាធរមាន សម្រាប់តម្រូវការរបស់ ក.ស.វ.
- ពង្រឹងនិងពង្រីកប្រព័ន្ធសម្របសម្រួល ទំនាក់ទំនង និងកិច្ចសហការជាមួយក្រសួង ស្ថាប័នជាតិ និងអន្តរជាតិនានាឱ្យបានល្អ និងមានប្រសិទ្ធភាព
- ជួយ ក.ស.វ. ក្នុងដំណើរការរៀបចំសិក្ខាសាលា និងផ្តល់នូវបទបង្ហាញលើប្រធានបទសំខាន់ៗដែលពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- បំពេញការងារផ្សេងទៀត តាមការប្រគល់ជូនរបស់ប្រធាន ក.ស.វ. ។

## ជំពូកទី៣
## រចនាសម្ព័ន្ធនិងការគ្រប់គ្រង

**មាត្រា ៣.-**

អគ្គលេខាធិការដ្ឋាន **ក.ស.ឆ.** ដឹកនាំដោយអគ្គលេខាធិការមួយរូប មានឋានៈស្មើរដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការ និងមានអគ្គលេខាធិការរងមួយចំនួន ជាជំនួយការតាមការចាំបាច់ ដែលមានឋានៈស្មើអនុរដ្ឋលេខាធិការ ឬអគ្គនាយក ។

អគ្គលេខាធិការរងបំពេញភារកិច្ចតាមការបែងចែកការងាររបស់អគ្គលេខាធិការ ។

អគ្គលេខាធិការនិងអគ្គលេខាធិការរង ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

**មាត្រា ៤.-**

អគ្គលេខាធិការដ្ឋាន **ក.ស.ឆ.** មានរចនាសម្ព័ន្ធដូចតទៅ ÷

- ផ្នែករដ្ឋបាល បុគ្គលិក និងពិធីការ
- ផ្នែកហិរញ្ញវត្ថុនិងផ្គត់ផ្គង់
- ផ្នែកវិភាគនិងព្យាករស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- ផ្នែកសិក្សា ស្រាវជ្រាវ និងអង្កេត
- ផ្នែកលិខិតបទដ្ឋានគតិយុត្ត
- ផ្នែកប្រព័ន្ធគ្រប់គ្រងឯកសារ ទិន្នន័យ និងព័ត៌មាន
- ផ្នែកទំនាក់ទំនងនិងកិច្ចសហការអន្តរជាតិ ។

អង្គការលេខនៃអគ្គលេខាធិការដ្ឋាន **ក.ស.ឆ.** ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ៥.-**

ផ្នែកនីមួយៗនៃអគ្គលេខាធិការដ្ឋាន **ក.ស.ឆ.** ដឹកនាំដោយប្រធានផ្នែកមួយរូប មានឋានៈស្មើអគ្គនាយករងឬប្រធាននាយកដ្ឋាន និងមានអនុប្រធានផ្នែកមួយចំនួនជាជំនួយការ ដែលមានឋានៈស្មើប្រធាននាយកដ្ឋានឬអនុប្រធាននាយកដ្ឋាន ។

ប្រធានផ្នែកនៃអគ្គលេខាធិការដ្ឋាន **ក.ស.ឆ.** ត្រូវតែងតាំងដោយអនុក្រឹត្យ ។

អនុប្រធានផ្នែកនៃអគ្គលេខាធិការដ្ឋាន **ក.ស.ឆ.** ត្រូវតែងតាំងដោយអនុក្រឹត្យឬដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៦.-**

ផ្នែកនីមួយៗនៃអគ្គលេខាធិការដ្ឋាន **ក.ស.ឆ.** អាចមានក្រុមបច្ចេកទេសមួយចំនួនក្នុងករណីចាំបាច់ ដើម្បីជួយការងារ ។

ក្រុមបច្ចេកទេសនីមួយៗត្រូវដឹកនាំដោយប្រធានក្រុមមួយរូប ដែលមានឋានៈស្មើប្រធានការិយាល័យ និងអាចមានអនុប្រធានក្រុមមួយចំនួនតាមការចាំបាច់ជាជំនួយការ ដែលមានឋានៈស្មើអនុប្រធានការិយាល័យ ។

ប្រធានក្រុមនិងអនុប្រធានក្រុមត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៧.-**

អគ្គលេខាធិការដ្ឋាន **គ.ស.ទ.** មានមន្ត្រីបម្រើការងារជាមន្ត្រីក្របខណ្ឌមុខងារសាធារណៈនៃទីស្តីការគណៈរដ្ឋមន្ត្រី។ ក្នុងករណីចាំបាច់ អគ្គលេខាធិការដ្ឋាន **គ.ស.ទ.** អាចមានបុគ្គលិកជាប់កិច្ចសន្យា ដើម្បីជួយបំពេញ ការងារ ។

## ជំពូកទី៤
## មុខងារនិងភារកិច្ចរបស់ផ្នែកនីមួយៗ

**មាត្រា ៨.-**

ផ្នែករដ្ឋបាល បុគ្គលិក និងពិធីការ មានមុខងារនិងភារកិច្ចដូចតទៅ ÷

- បំពេញការងាររដ្ឋបាល ក្នុងដំណើរការការងារប្រចាំថ្ងៃរបស់ **គ.ស.ទ.**
- រៀបចំផែនការគ្រប់គ្រងបុគ្គលិកនិងមន្ត្រីរាជការទាំងអស់នៃអគ្គលេខាធិការដ្ឋាន **គ.ស.ទ.**
- រៀបចំផែនការបណ្តុះបណ្តាលនានា សម្រាប់ពង្រឹងនិងបង្កើនសមត្ថភាពរបស់មន្ត្រីនៃអគ្គលេខាធិការដ្ឋាន **គ.ស.ទ.**
- បំពេញការងារពិធីការ សម្រាប់កិច្ចប្រជុំនិងសកម្មភាពការងារដទៃទៀតរបស់ **គ.ស.ទ.**
- រៀបចំព្រឹត្តិបត្រប្រចាំខែនិងព្រឹត្តិបត្រដទៃទៀតរបស់ **គ.ស.ទ.**
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ **គ.ស.ទ.** ប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំ
- បំពេញការងារផ្សេងទៀត តាមការប្រគល់ជូនរបស់អគ្គលេខាធិការនៃ **គ.ស.ទ.** ។

**មាត្រា ៩.-**

ផ្នែកហិរញ្ញវត្ថុនិងផ្គត់ផ្គង់ មានមុខងារនិងភារកិច្ចដូចតទៅ ÷

- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ **គ.ស.ទ.** និងបំពេញការងារផ្គត់ផ្គង់ជូន **គ.ស.ទ.**
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំរបស់ **គ.ស.ទ.**
- ស្វែងរកលទ្ធភាពដែលអាចទទួលបាននូវថវិកាពីប្រភព ថវិការដ្ឋ ជំនួយ អំណោយនានា ដើម្បីបង្កើនថវិកាប្រចាំឆ្នាំរបស់ **គ.ស.ទ.**
- គ្រប់គ្រងចលនទ្រព្យរបស់ **គ.ស.ទ.**
- បំពេញការងារផ្សេងទៀត តាមការប្រគល់ជូនរបស់អគ្គលេខាធិការនៃ **គ.ស.ទ.** ។

**មាត្រា ១០.-**

ផ្នែកវិភាគនិងព្យាករស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានមុខងារនិងភារកិច្ចដូចតទៅ ÷

- ប្រមូលទិន្នន័យនិងព័ត៌មានសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រចាំខែ និងប្រចាំឆ្នាំ
- រៀបចំតារាងទិន្នន័យនៃស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ដែលវិវត្តប្រចាំខែ ប្រចាំឆ្នាំ ជូន **គ.ស.ច.** ដើម្បីធ្វើការវិភាគនិងរកមូលហេតុ រួចរាយការណ៍ជូនរាជរដ្ឋាភិបាល
- ចងក្រងសៀវភៅស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ប្រចាំខែនិងប្រចាំឆ្នាំ
- ធ្វើជាជំនួយការបច្ចេកទេសជូន **គ.ស.ច** សម្រាប់ធ្វើការព្យាករបញ្ហាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលអាចកើតមានឡើងនាពេលអនាគត
- បំពេញការងារផ្សេងទៀត តាមការប្រគល់ជូនរបស់អគ្គលេខាធិការនៃ **គ.ស.ច.** ។

**មាត្រា ១១.-**

ផ្នែកសិក្សា ស្រាវជ្រាវ និងអង្កេត មានមុខងារនិងភារកិច្ចដូចតទៅ ÷

- សិក្សា ស្រាវជ្រាវលើប្រធានបទដែលជាបញ្ហាប្រឈមសំខាន់ៗពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌តាមការកំណត់របស់ **គ.ស.ច.**
- ធ្វើអង្កេតលើប្រធានបទពិសេសដែល **គ.ស.ច.** បានកំណត់ឱ្យតាមកាលបរិច្ឆេទនិងរយៈពេលច្បាស់លាស់ ដោយត្រូវ :
    - រៀបចំផែនការការងារ កម្រងសំណួរចម្លើយ និងវិធីសាស្ត្រសម្រាប់ធ្វើអង្កេត
    - ប្រមូលនិងបញ្ចូលទិន្នន័យអង្កេតក្នុងប្រព័ន្ធវិភាគ
    - ធ្វើការវិភាគលើទិន្នន័យ និងព័ត៌មានដែលបានមកពីអង្កេត
- រៀបចំរបាយការណ៍លទ្ធផលនៃការសិក្សា ការស្រាវជ្រាវ និងអង្កេតខាងលើជូន **គ.ស.ច.** សម្រាប់ ពិនិត្យនិងផ្តល់យោបល់ជូនរាជរដ្ឋាភិបាល
- បំពេញការងារផ្សេងទៀត តាមការប្រគល់ជូនរបស់អគ្គលេខាធិការនៃ **គ.ស.ច.** ។

**មាត្រា ១២.-**

ផ្នែកលិខិតបទដ្ឋានគតិយុត្ត មានមុខងារនិងភារកិច្ចដូចតទៅ ÷

- រៀបចំឯកសារយោងនិងពាក់ព័ន្ធនានាសម្រាប់កិច្ចប្រជុំរបស់ **គ.ស.ច.** ក្នុងដំណើរការពិនិត្យនិងផ្តល់ យោបល់លើសេចក្តីព្រាងឯកសារ លិខិតបទដ្ឋានគតិយុត្ត ដែលបណ្តាក្រសួង ស្ថាប័នដាក់ស្នើមក ទីស្តីការគណៈរដ្ឋមន្ត្រី

- ធ្វើទំនាក់ទំនងនិងកិច្ចសហការយ៉ាងជិតស្និទ្ធ ជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីបំពេញការងារខាងលើ
- សម្របសម្រួលការធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំលើកទី១
- តាមដានសេចក្តីព្រាងឯកសារ លិខិតបទដ្ឋានគតិយុត្តដែលបានឆ្លងកិច្ចប្រជុំលើកទី១
- រៀបចំវិធីសាស្ត្រវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
- រៀបចំតាក់តែងឯកសារ លិខិតបទដ្ឋានគតិយុត្ត តាមការកំណត់របស់ **ក.ស.វ.**
- បំពេញការងារផ្សេងទៀត តាមការប្រគល់ជូនរបស់អគ្គលេខាធិការនៃ **ក.ស.វ.** ។

**មាត្រា ១៣.-**

ផ្នែកប្រព័ន្ធគ្រប់គ្រងឯកសារ ទិន្នន័យ និងព័ត៌មាន មានមុខងារនិងភារកិច្ចដូចតទៅ ៖

- ចងក្រងឯកសារលិខិតបទដ្ឋានគតិយុត្តជាធរមាន តាមរយៈប្រព័ន្ធគ្រប់គ្រងព័ត៌មានមួយសមស្រប
- ចងក្រងទិន្នន័យនិងព័ត៌មាន វិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលបានពីក្រសួងស្ថាប័នឬពីប្រភពដទៃទៀត
- រៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មាន ឱ្យឆ្លើយតបនឹងតម្រូវការរបស់ **ក.ស.វ.** ទាន់ពេលវេលានិងប្រកបដោយប្រសិទ្ធភាព
- បង្កើតនិងគ្រប់គ្រងគេហទំព័ររបស់ **ក.ស.វ.**
- រៀបចំនិងគ្រប់គ្រងបណ្ណាល័យ សម្រាប់តម្រូវការឯកសាររបស់ **ក.ស.វ.**
- បំពេញការងារផ្សេងទៀត តាមការប្រគល់ជូនរបស់អគ្គលេខាធិការនៃ **ក.ស.វ.** ។

**មាត្រា ១៤.-**

ផ្នែកទំនាក់ទំនងនិងកិច្ចសហការអន្តរជាតិ មានមុខងារនិងភារកិច្ចដូចតទៅ ៖

- រៀបចំប្រព័ន្ធទំនាក់ទំនងនិងធ្វើកិច្ចសហការជាមួយសង្គមស៊ីវិល ផ្នែកឯកជន អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍ ដើម្បីផ្លាស់ប្តូរបទពិសោធ ទិន្នន័យ និងព័ត៌មាន លើវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- ស្វែងរកដៃគូផ្តល់ជំនួយផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ ដែលគាំទ្រដល់កិច្ចដំណើរការការងាររបស់ **ក.ស.វ.**
- ស្វែងរកកិច្ចសហការក្នុងការបណ្តុះបណ្តាល ដើម្បីបង្កើនសមត្ថភាពនិងប្រសិទ្ធភាពការងាររបស់ **ក.ស.វ.**
- ធ្វើទំនាក់ទំនងរកអ្នកជំនាញការអន្តរជាតិផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សម្រាប់ជួយការងារជាទីប្រឹក្សាបច្ចេកទេសជូន **ក.ស.វ.**
- រៀបចំសិក្ខាសាលានិងការផ្តល់បទបង្ហាញរបស់ **ក.ស.វ.** ដោយសហការជាមួយអ្នកឧបត្ថម្ភ
- បំពេញការងារផ្សេងទៀត តាមការប្រគល់ជូនរបស់អគ្គលេខាធិការនៃ **ក.ស.វ.** ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា ១៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ៣ ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣០១ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តកំពង់ស្ពឺ

**សម្រេច**

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ប្រគេនព្រះសង្ឃ និងជូនសប្បុរសជន ចំនួន ២៥ រូប ដែលមានគុណបំណាច់ខ្ពស់ ក្នុងការចូលរួមជួយកសាងសមិទ្ធផលផ្សេងៗ ក្នុងវិស័យព្រះពុទ្ធសាសនា នៅវត្ត វណ្ណៈរង្សី ហៅវត្តសំរោង ស្ថិតក្នុងឃុំមានោរម្យ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ដូចមានរាយព្រះនាម និងនាមខាងក្រោម :-

**ក_មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ :**

| | | | | | |
|---|---|---|---|---|---|
| ១-ព្រះតេជគុណ | **ទឹម** | **សឿង** | ៣-លោក | **ឡាយ** | **កង** |
| ២-លោក | **ឈុយ** | **ឡាំ** | ៤-លោក | **ជួប** | **ឆាយ** |

**ខ_មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា :**

| | | | | | |
|---|---|---|---|---|---|
| ១-ព្រះតេជគុណ | **ហៀក** | **ឡឹង** | ៧-លោក | **តឿង** | **តឿន** |
| ២-ព្រះតេជគុណ | **ជួប** | **គុណា** | ៨-លោក | **អ៊ុំ** | **សុត** |
| ៣-លោក | **ឈឹម** | **ជា** | ៩-លោក | **យូ** | **រ៉ាន** |
| ៤-លោកស្រី | **យឹម** | **ឡាង** | ១០-លោក | **សែម** | **ថុល** |
| ៥-លោក | **ម៉ឺន** | **សុខុម** | ១១-លោក | **អ៊ុច** | **ឆឿន** |
| ៦-លោក | **នែម** | **សារឿន** | ១២-លោក | **ស្រ៊ុប** | **ស្រ៊ី** |

**គ_មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ :**

| | | | | | |
|---|---|---|---|---|---|
| ១-លោក | **ប៉ុល** | **ឆាន** | ៦-លោក | **យង់** | **សារិន** |
| ២-លោក | **អ៊ឹម** | **ប៊ិន** | ៧-លោក | **លិញ** | **សុខ** |
| ៣-លោក | **សុខ** | **លាង** | ៨-លោក | **ឡុង** | **នឿន** |
| ៤-លោក | **ដេង** | **ខាន់** | ៩-លោក | **ញ៉ឹប** | **សុផល** |
| ៥-លោក | **លី** | **ហេង** | | | |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៣០៧ អនក្រ.តត**

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់មេដាយ នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ជូន នាយនគរបាលជាតិ មន្ត្រីរាជការ និងសប្បុរសជន ដែលបានរួមចំណែកយ៉ាងសកម្មក្នុងការការពារ សន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គមជូនប្រជាពលរដ្ឋ និងបានបរិច្ចាកទ្រព្យធនផ្ទាល់ខ្លួន ដើម្បីកសាងអភិវឌ្ឍន៍លើគ្រប់វិស័យក្នុងស្រុកសង្កែ ខេត្តបាត់ដំបង ដូចរាយនាមខាងក្រោម :

**ក- មេដាយ មុនីសារាភ័ណ្ឌ ថ្នាក់ សេនា**

| | | |
|---|---|---|
| ១- លោក | ម៉ោញ កំសាន្ត | អនុប្រធាននាយកដ្ឋាន នគរបាលបច្ចេកទេសវិទ្យាសាស្ត្រ |
| ២- លោក | ជាវ ផាន់លី | អនុប្រធានទី១ នាយកដ្ឋាន នគរបាលបច្ចេកទេសវិទ្យាសាស្ត្រ |
| ៣- លោក | ហាក មជ្ឈីរ៉ា | អនុប្រធាននាយកដ្ឋាន នគរបាលបច្ចេកទេសវិទ្យាសាស្ត្រ |
| ៤- លោក | មួង សុធា | អនុប្រធាននាយកដ្ឋាន នគរបាលបច្ចេកទេសវិទ្យាសាស្ត្រ |
| ៥- លោក | ទិត្យ ប៊ុនណា | អនុប្រធាននាយកដ្ឋាន នគរបាលបច្ចេកទេសវិទ្យាសាស្ត្រ |
| ៦- លោក | ឈុន ចាន់សុខា | នាយការិយាល័យ នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ |

| | | |
|---|---|---|
| ៧- លោក | សរ វ៉ាន់ថុន | នាយការិយាល័យ នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ |
| ៨- លោក | ស្រី សុផាណារិទ្ធ | នាយការិយាល័យ នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ |
| ៩- លោក | យិន ប៊ុន | នាយការិយាល័យ នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ |
| ១០- លោក | ឡឹក សុធា | នាយការិយាល័យ នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ |
| ១១- លោក | ងួន វណ្ណរ័ត្ននី | នាយការិយាល័យ នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ |
| ១២- លោក | រស់ គីមឈាង | សប្បុរសជនក្រុងភ្នំពេញ |

**ខ. មេដាយ មុនីសារាភ័ណ្ឌ ថ្នាក់ អសិរិឫទ្ធិ**

| | | |
|---|---|---|
| ១- លោក | ហ៊ុន សុភាព | នាយការិយាល័យ នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ |
| ២- លោក | ទឿង សុផានី | នាយការិយាល័យ នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ |
| ៣- លោក | អ៊ុង កាណារ៉ែន | នាយការិយាល័យ នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ |
| ៤- លោក | សុខ ត្រី | នាយផ្នែក នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ |
| ៥- លោក | យឹម វណ្ណហុង | នាយផ្នែក នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ |
| ៦- លោក | ប៉ា សំម៉ារឌី | នាយផ្នែក នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ |
| ៧- លោក | ឡាក់ សេង | នាយផ្នែក នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ |
| ៨- លោក | គា វណ្ណី | នាយរងផ្នែក នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ |
| ៩- លោក | លឹម ស៊ាងគ្រី | នាយរងផ្នែក នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ |
| ១០- លោក | គីម សុវណ្ណារ៉ា | នាយរងផ្នែក នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ |
| ១១- លោក | ម៉ែន ផលវីរៈ | នាយរងផ្នែក នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ |
| ១២- លោក | សួន ពិសិដ្ឋ | នាយរងផ្នែក នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបាត់ដំបងត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ មាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣០៣ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់មេដាយ នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់មេដាយការងារ តាមលំដាប់ថ្នាក់ជូន នាយនគរបាលជាតិ មន្ត្រីរាជការ ដែលបានរួមចំណែកយ៉ាងសកម្មក្នុងការការពារ សន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម ជូនប្រជាពលរដ្ឋ និងបានបរិច្ចាកទ្រព្យធនផ្ទាល់ខ្លួន ដើម្បីកសាងអភិវឌ្ឍន៍លើគ្រប់វិស័យក្នុង ស្រុកសង្កែ ខេត្តបាត់ដំបង ដូចរាយនាមខាងក្រោម :

**- មេដាយការងារ ថ្នាក់មាស**

| | | | |
|---|---|---|---|
| ១- | លោក | ឡុង ច័ន្ទឌឿន | នាយការិយាល័យ នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ |
| ២- | លោក | ជែន ជ័យ | នាយរងការិយាល័យ នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ |
| ៣- | លោក | អ៊ុំង ច័ន្ទសុវណ្ណ | ជំនួយការប្រធាននាយកដ្ឋាន នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ |
| ៤- | លោក | ហ៊ុន លឹមហាក់ | នាយរងការិយាល័យ នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ |
| ៥- | លោក | អ៊ុំង សុផល | នាយរងការិយាល័យ នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ |

៦- លោក អុំ សុផល នាយរងការិយាល័យ នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ

៧- លោក តួង ឆុង នាយរងការិយាល័យ នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ

៨- លោក សុង សារិន នាយរងការិយាល័យ នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ

៩- លោក ប៉ែន វណ្ណឌី នាយផ្នែក នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ

១០- លោក ប៊ុន វិយុត នាយរងការិយាល័យ នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ

១១- លោក ចាច ស៊ុម នាយរងការិយាល័យ នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ

១២- លោក លាង ឌីពីលី នាយរងការិយាល័យ នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ

១៣-លោក វ៉ា ផល្លា នាយរងផ្នែក នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ

១៤- លោក អ៊ូច សុគន្ធពិដោរ មន្ត្រី នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបាត់ដំបងត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ មាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៣០៤ អនក្រ.តត**

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការការងារចាំបាច់

### សម្រេច

**មាត្រា ១** : តែងតាំងមន្ត្រីចំនួន ០២ រូប ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ អគ្គនាយករង ដូចមាននាមខាងក្រោម ÷

- លោក **ហេង ហាក់លីម**
- លោក **សៅ សុគុ:**

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣០៥ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ០៣រូប ដែលបានបរិច្ចាគថវិកាចូលរួមជួយកសាងសមិទ្ធផលសាធារណៈផ្សេងៗ នៅក្នុងមូលដ្ឋានស្រុកត្រាំកក់ ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម :-

**ក_មេដាយមាសស្ថាបនាជាតិ :**

១-ឯកឧត្តម **សួស អង្គារ៉** បរិច្ចាគថវិកា ចំនួន ២០.០០០ ដុល្លារ

២-លោក **ញៀម តារារិទ្ធ** បរិច្ចាគថវិកា ចំនួន ២០.០០០ ដុល្លារ

**ខ_មេដាយប្រាក់ស្ថាបនាជាតិ :**

-លោក **អៀង សារ៉េត** បរិច្ចាគថវិកា ចំនួន ៥.០០០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣០៦ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

**សម្រេច**

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ០៥រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផលសាធារណៈផ្សេងៗ នៅស្រុកត្រាំកក់ ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :**

| | | | |
|---|---|---|---|
| ១-ឧកញ៉ា | **ខូច** | **ផល្លាបុត្រ** | ថវិកា ចំនួន ៨០.០០០ ដុល្លារ |
| ២-ឧកញ៉ា | **ទ្រី** | **តាត** | ថវិកា ចំនួន ៨០.០០០ ដុល្លារ |
| ៣-លោក | **ម៉ៅ** | **តន** | ថវិកា ចំនួន ៨០.០០០ ដុល្លារ |

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :**

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **សៅរ៉ុក** | **ពិសិដ្ឋ** | ថវិកា ចំនួន ៤០.០០០ ដុល្លារ |
| ២-ឯកឧត្តម | **ម៉ែន** | **ស៊ីផាន់** | ថវិកា ចំនួន ៤០.០០០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញថ្ងៃទី ០៤ ខែ ៣ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៣០៧ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់មេបញ្ជាការកងទ័ពជើងគោក

### សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូននាយទាហាន និងពលទាហាន ចំណុះតំបន់ប្រតិបត្តិការសឹករងកណ្តាល ចំនួន៧៦រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម :-

**ក.មេដាយមាសការងារ :**

| | | | | |
|---|---|---|---|---|
| ១ | អនុសេនីយ៍ឯក | ឆន ឧត្តរា | ០២៧៨៣៧ | នាយរងផ្នែកលេខាធិការដ្ឋាន |
| ២ | អនុសេនីយ៍ឯក | ណោង សំអួន | ០៤០៨៤៩ | នាយរងការិយាល័យទី ៣ |
| ៣ | អនុសេនីយ៍ឯក | នុត សាខន | ០១៥៣០៨ | នាយរងការិយាល័យទី ៤ |
| ៤ | អនុសេនីយ៍ឯក | ណោង សំអួន | ០៤០៨៤៩ | នាយរងការិយាល័យទី ៣ |
| ៥ | អនុសេនីយ៍ឯក | នៅ ឆន | ០១៥៣១៥ | នាយរងការិយាល័យទី ៥ |
| ៦ | អនុសេនីយ៍ឯក | ឃួន ភិរម្យ | ០១៥៣១៦ | មេបញ្ជាការវរសេនាតូច ១ |
| ៧ | អនុសេនីយ៍ទោ | កែវ ចាន់លី | ០៤០៨៤១ | នាយរងការិយាល័យទី ៤ |
| ៨ | អនុសេនីយ៍ទោ | ពេជ គីឡា | ០៥៦៧០៤ | មេបញ្ជាការរងវរសេនាតូច ១ |

| | | | | |
|---|---|---|---|---|
| ៩ | អនុសេនីយ៍ទោ | ថាច់ ចាន់ដារ៉ា | ០៦៣៦៩៥ | ជំនួយការការិយាល័យទី ៣ |
| ១០ | អនុសេនីយ៍ត្រី | ជា ស៊ីថន | ០២៧៨១៦ | ជំនួយការបុគ្គលិក លេខា |
| ១១ | នាយចំណង់ | អ៊ុំ ពៅ | ០៥៦៧១២ | មេបញ្ជាការរងវរសេនាតូច ១ |
| ១២ | ព្រិន្ទបាលឯក | ផុន ជឿន | ១៤៩៩៧៣ | ជំនួយការបញ្ជូនសារ |

**ខ. មេជាយឆ្មាក់ការខារ :**

| | | | | |
|---|---|---|---|---|
| ១ | អនុសេនីយ៍ឯក | ឆាំ ឆុច | ១៤៩៨៩៦ | មេបញ្ជាការរងផ្នែកសឹករងលើកដែក |
| ២ | អនុសេនីយ៍ឯក | ឡោ អេន | ០១៥៣៣៣ | មេបញ្ជាការរងផ្នែកសឹករងមុខកំពូល |
| ៣ | អនុសេនីយ៍ឯក | ចេង សុផល | ០២៧៨៤៥ | នាយរងការិយាល័យទី ៥ |
| ៤ | អនុសេនីយ៍ឯក | ចូវ សុផល | ០២៧៨២២ | ជំនួយការបុគ្គលិកការិយាល័យទី ១ |
| ៥ | អនុសេនីយ៍ឯក | ផាន សុផាន់ | ០២៧៨៥៦ | នាយរងការិយាល័យអភិវឌ្ឍន៍ |
| ៦ | អនុសេនីយ៍ឯក | ចូវ សុភា | ០២៧៨២៦ | នាយរងការិយាល័យទី ១ |
| ៧ | អនុសេនីយ៍ឯក | កែវ លន់ | ០៤០៨៤០ | ជំនួយការតែងតាំង ការិយាល័យទី១ |
| ៨ | អនុសេនីយ៍ឯក | ជា សុខា | ០៤០៨៣១ | ជំនួយការតែងតាំង ការិយាល័យទី១ |
| ៩ | អនុសេនីយ៍ឯក | អេង ម៉ានិត | ០៥៦៧១៥ | ជំនួយការហិរញ្ញវត្ថុ |
| ១០ | អនុសេនីយ៍ឯក | អឿន សុធីរឧត្តម | ០២៧៨៤៤ | នាយរងការិយាល័យអភិវឌ្ឍន៍ |
| ១១ | អនុសេនីយ៍ឯក | ណន សុគន្ធ | ០១៥៣១៩ | មេបញ្ជាការរងផ្នែកសឹករងខ្សាច់កណ្តាល |
| ១២ | អនុសេនីយ៍ឯក | ព្រហ្ម ស៊ីណា | ០១៥៣៣៥ | មេបញ្ជាការរងផ្នែកសឹករងកៀនស្វាយ |
| ១៣ | អនុសេនីយ៍ឯក | ជឹម ប៊ុនធឹម | ០១៥៣២៨ | មេបញ្ជាការរងផ្នែកសឹករងពញាឮ |
| ១៤ | អនុសេនីយ៍ឯក | វ៉ែន វឿន | ០១៥៣៣១ | មេបញ្ជាការរងផ្នែកសឹករងអង្គស្នួល |
| ១៥ | អនុសេនីយ៍ឯក | ចាន់ រិទ្ធី | ០១៥៣៣២ | មេបញ្ជាការរងផ្នែកសឹករងកណ្តាលស្ទឹង |
| ១៦ | អនុសេនីយ៍ឯក | ផាង សារឹម | ០៦៣៥៨៧ | មេបញ្ជាការរងផ្នែកសឹករងពញាឮ |
| ១៧ | អនុសេនីយ៍ឯក | ស៊ឹង សារ៉ាន្ត | ០៥៦៧៤៩ | មេបញ្ជាការរងផ្នែកសឹករងអង្គស្នួល |
| ១៨ | អនុសេនីយ៍ឯក | តាំង ម៉េងគង់ | ០៦៣៦៨៦ | មេបញ្ជាការរងផ្នែកសឹករងមុខកំពូល |
| ១៩ | អនុសេនីយ៍ឯក | វ៉ែត សុវណ្ណា | ០៥៦៧០៧ | នាយសេនាធិការវរសេនាតូចលេខ ១ |
| ២០ | អនុសេនីយ៍ឯក | គិន ហឿន | ០៥៦៧០០ | ជំនួយការហិរញ្ញវត្ថុ វរសេនាតូចលេខ ១ |
| ២១ | អនុសេនីយ៍ឯក | ភាន់ សារិន | ០៥៦៧៣៩ | ជំនួយការហិរញ្ញវត្ថុ |
| ២២ | អនុសេនីយ៍ឯក | ស៊ុំ សុវណ្ណរិទ្ធ | ០៤០៨៦២ | ជំនួយការឯកសារ ការិយាល័យទី ១ |
| ២៣ | អនុសេនីយ៍ទោ | សុខ ប៊ុនហៀង | ០៦៣៦៥៥ | ជំនួយការសោធននិវត្តន៍ ការិ.ទី ១ |
| ២៤ | អនុសេនីយ៍ទោ | ហង្ស វណ្ណា | ០៩១៦៧៨ | ជំនួយការបណ្តុះបណ្តាល ការិ.ទី ១ |

| | | | | |
|---|---|---|---|---|
| ២៥ | អនុសេនីយ៍ទោ | ឈឹម ឆេង | ០២៧៨៥៩ | នាយរងការិយាល័យហ្វឹកហ្វឺន |
| ២៦ | អនុសេនីយ៍ទោ | ប៉េង សេងលី | ០៥៦៦៥២ | ជំនួយការប្រេង ការិយាល័យទី ៤ |

**គ.មេបញ្ជាការរងទ័ពជើងទឹក**

| | | | | |
|---|---|---|---|---|
| ១ | អនុសេនីយ៍ទោ | ញៀម ម៉ុនថា | ០២៧៨២៥ | នាយរង ផ្នែកបញ្ជូនសារ |
| ២ | អនុសេនីយ៍ទោ | ខេង ម៉ុនធឿន | ០៦៣៥៨៣ | ជំនួយការប្រតិបត្តិការសឹកលើកដែក |
| ៣ | អនុសេនីយ៍ទោ | ឯម ចាន់សារ៉ាវុធ | ១១៣២១៨ | ជំនួយការចិត្តសាស្ត្រ លើកដែក |
| ៤ | អនុសេនីយ៍ទោ | ឈយាង ឈី | ០៦៣៦៤៦ | មេបញ្ជាការរង គ កោះធំ |
| ៥ | អនុសេនីយ៍ទោ | ហ៊ាង សេងហុង | ០៥៦៧០៣ | មេបញ្ជាការរង គ កោះធំ |
| ៦ | អនុសេនីយ៍ទោ | ចាន់ ពុត | ០៥៦៧៦៦ | ជំនួយការចលនូប្បត្ថម្ភ ខ្សាច់កណ្តាល |
| ៧ | អនុសេនីយ៍ទោ | ជ័យ សុផាត | ០៥៦៧៧៥ | ជំនួយការចលនូប្បត្ថម្ភ កណ្តាលស្ទឹង |
| ៨ | អនុសេនីយ៍ទោ | នៅ កុដ | ០៦៣៧៣ | ជំនួយការប្រតិបត្តិការសឹក មុខកំពូល |
| ៩ | អនុសេនីយ៍ទោ | សួន បូរ៉ា | ០៦៣៦៨១ | ជំនួយការចិត្តសាស្ត្រ មុខកំពូល |
| ១០ | អនុសេនីយ៍ទោ | ហោម បុន្នមរ័ត្ន | ០៥៦៧៥៨ | បុគ្គលិកពេទ្យ កៀនស្វាយ |
| ១១ | អនុសេនីយ៍ទោ | សួង សុផល | ០៩១៦១៥ | ជំនួយការប្រតិបត្តិការសឹក កៀនស្វាយ |
| ១២ | អនុសេនីយ៍ទោ | ជា សាវុធ | ០៦៣៦២២ | មេបញ្ជាការរង គ១ វរសេនាតូច ១ |
| ១៣ | អនុសេនីយ៍ទោ | មុំ វុត្ថា | ១៣៨៩៧៦ | មេបញ្ជាការរង គ៣ វរ.តូចលេខ ១ |
| ១៤ | អនុសេនីយ៍ទោ | ស្រី ណារ៉ុង | ០៦៣៥៩០ | មេក្រុម វរសេនាតូចលេខ ១ |
| ១៥ | អនុសេនីយ៍ត្រី | ថុន វាសនា | ១៤៩៩៦៤ | ជំនួយការ ការិយាល័យអភិវឌ្ឍន៍ |
| ១៦ | អនុសេនីយ៍ត្រី | សុខ ណារិទ្ធ | ០៨៤៨៦១ | ជំនួយការចិត្តសាស្ត្រ តាខ្មៅ |
| ១៧ | អនុសេនីយ៍ត្រី | ឯម ភារម្យ | ០៥៦៦៩៥ | ជំនួយការចលនូប្បត្ថម្ភ តាខ្មៅ |
| ១៨ | អនុសេនីយ៍ត្រី | គុំ យ៉ាតតិ | ១៥០០១៣ | ជំនួយការហ្វឹកហ្វឺន កណ្តាលស្ទឹង |
| ១៩ | នាយចំណង់ | ចាន់ សុខុម | ០៤០៨៥៧ | នាយរងការិយាល័យហ្វឹកហ្វឺន |
| ២០ | ព្រិន្ទបាលឯក | អ៊ុំ ស៊ិន | ០៤៨៨៨៩ | ជំនួយការបុគ្គលិក អង្គស្នួល |
| ២១ | ព្រិន្ទបាលឯក | ឡាយ ម៉េង | ០៩១៦៦៣ | ជំនួយការប្រតិបត្តិការសឹក អង្គស្នួល |
| ២២ | ព្រិន្ទបាលឯក | ឈុំ រិទ្ធី | ០៦៣៦៥១ | មេបញ្ជាការ ខ៣ កោះធំ |
| ២៣ | ព្រិន្ទបាលឯក | សុត្រ ជា | ១៤៩៩២៤ | ជំនួយការប្រតិបត្តិការសឹក ស្អាង |
| ២៤ | ព្រិន្ទបាលឯក | យ៉ន យ៉ុង | ០៩១៥៩៣ | ជំនួយការវិទ្យុទាក់ទង ស្អាង |
| ២៥ | ព្រិន្ទបាលឯក | ហេង ម៉េងហ៊ុន | ០៦៣៦៣៨ | ជំនួយការចលនូប្បត្ថម្ភ ស្អាង |
| ២៦ | ព្រិន្ទបាលឯក | ភួង ផាត | ០៩១៦៤០ | ជំនួយការចិត្តសាស្ត្រ ខ្សាច់កណ្តាល |

| | | | | |
|---|---|---|---|---|
| ២៧ | ព្រិន្ទបាលឯក | **ហ៊ុល ស៊ុយ** | ០៥៦៧៤៣ | ជំនួយការចលនូប្បត្ថម្ភ កណ្តាលស្ទឹង |
| ២៨ | ព្រិន្ទបាលឯក | **គុយ សុធា** | ០៦៣៦៨៩ | ជំនួយការចលនូប្បត្ថម្ភ កណ្តាលស្ទឹង |
| ២៩ | ព្រិន្ទបាលឯក | **រឹម ប៊ូរី** | ១៤៩៩៣០ | ជំនួយការយោធាតំបន់ កៀនស្វាយ |
| ៣០ | ព្រិន្ទបាលឯក | **គីម ផាន់** | ០៦៣៦៦០ | ជំនួយការបុគ្គលិក ពញាឮ |
| ៣១ | ព្រិន្ទបាលឯក | **ណម ណារី** | ០៦៣៦៦១ | ជំនួយការប្រតិបត្តិការសឹក ពញាឮ |
| ៣២ | ព្រិន្ទបាលឯក | **សំ សុគា** | ០៥៦៧៥១ | ជំនួយការចលនូប្បត្ថម្ភ ពញាឮ |
| ៣៣ | ព្រិន្ទបាលទោ | **ឡាច លឿន** | ១៣៨៩៧៣ | ជំនួយការហ្វឹកហ្វឺន តាខ្មៅ |
| ៣៤ | ព្រិន្ទបាលទោ | **គង់ វណ្ណា** | ០៦៣៩៧៧ | មេបញ្ជាការ ខ១ គ១ វរ.តូច ១ |
| ៣៥ | ពលបាលឯក | **រស់ សារិក** | ០៩១១០៩ | ជំនួយការហ្វឹកហ្វឺន អង្គស្នួល |
| ៣៦ | ពលបាលឯក | **សយ ស៊ឹម** | ០៩១៦៤៤ | ជំនួយការហ្វឹកហ្វឺន ខ្សាច់កណ្តាល |
| ៣៧ | ពលបាលឯក | **ម៉ុន ម៉ន** | ១៣៨៩៨០ | មេបញ្ជាការ ខ១ គ១ វរ.តូច ១ |
| ៣៨ | ពលបាលទោ | **គិត រតនៈ** | ០៩១៥៨៩ | មេបញ្ជាការ ខ ការពារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង មេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣០៤. អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ទោ **នៃ ចារី** អត្តលេខ ០៤៤៤ ពីអភិបាលរងខេត្តកណ្តាល ទៅជាអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចក្នុងមាត្រា១ ខាងលើត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២០៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការដំឡើងថ្នាក់តាមសញ្ញាបត្រជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : ត្រូវបានដំឡើងថ្នាក់តាមសញ្ញាបត្រជូនមន្ត្រីរាជការស៊ីវិល នៃក្រសួងមហាផ្ទៃ ចំនួន ០៣ រូប ដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| ១- | **លោក ពេជ្រ ចាន់** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅជាវរមន្ត្រី ថ្នាក់លេខ ៣ |
| ២- | **លោក អ៊ុន ប៊ូរ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ទៅជាវរមន្ត្រី ថ្នាក់លេខ ៥ |
| ៣- | **លោក អ៊ី សំអួន** | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅជាវរមន្ត្រី ថ្នាក់លេខ ៦ |

**មាត្រា ២** : បៀវត្សមូលដ្ឋានត្រូវបានអនុវត្តគិតចាប់ពីថ្ងៃចេញអនុក្រឹត្យនេះ ដោយរក្សាទុកអតីតភាពសំរាប់ឡើងថ្នាក់តាមវេនជ្រើសរើស និងវេនអតីតភាពឱ្យនៅដដែល ។

**មាត្រា ៣** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ដូចមាត្រា ៤ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣០០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា ជូនអស់លោក លោកស្រី ជាមន្ត្រីរាជការស៊ីវិល និង កងកំលាំងប្រដាប់អាវុធចំនួន ១១ រូប ដែលមានស្នាដៃក្នុងការបំពេញភារកិច្ចជូនជាតិបានល្អប្រសើរ ដូចមានរាយនាមខាងក្រោម :

១-លោក អែម សុខលាង អភិបាលរងខណ្ឌមានជ័យ រាជធានីភ្នំពេញ
២-លោក អ៊ាង ស៊ីផាន អភិបាលរងខណ្ឌមានជ័យ រាជធានីភ្នំពេញ
៣-លោក ហ៊ុយ សារុណា អភិបាលរងខណ្ឌមានជ័យ រាជធានីភ្នំពេញ
៤-លោក នៃ ផាត់ អភិបាលរងខណ្ឌមានជ័យ រាជធានីភ្នំពេញ
៥-លោក ព្រំ សុគាន អភិបាលរងខណ្ឌមានជ័យ រាជធានីភ្នំពេញ
៦-លោក ទ្រាដូ សីហា អភិបាលរងខណ្ឌមានជ័យ រាជធានីភ្នំពេញ
៧-លោក ថោង ចន្ថា អភិបាលរងខណ្ឌមានជ័យ រាជធានីភ្នំពេញ
៨-លោក សាន វិសាល ប្រធានមន្ទីរខណ្ឌមានជ័យ រាជធានីភ្នំពេញ

៩-លោក **ហាវ សុខុម** អនុប្រធានមន្ទីរខណ្ឌមានជ័យ រាជធានីភ្នំពេញ

១០-លោក **ហ៊ី សារិន** អធិការនគរបាលខណ្ឌមានជ័យ រាជធានីភ្នំពេញ

១១-លោក **សៀង នាយ** មេបញ្ជាការកងរាជអាវុធហត្ថខណ្ឌមានជ័យ រាជធានីភ្នំពេញ

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ០២ ឆ្នាំ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ..៣១១..អនក្រ.តត**

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនអស់លោក លោកស្រី មន្ត្រីរាជការស៊ីវិល និងកងកំលាំងប្រដាប់អាវុធចំនួន ៥៣ រូប ដែលមានស្នាដៃឆ្នើមក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិបានល្អ ដូចមានរាយនាមខាងក្រោម :

ក. **មេដាយមាសការងារ**

| | | |
|---|---|---|
| ១-លោក | ម៉ឹត ម៉ិុយ | ប្រធានការិយាល័យរដ្ឋបាលទូទៅខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| ២-លោក | សាយ មុយឡេង | ប្រធានការិយាល័យសេដ្ឋកិច្ចខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| ៣-លោក | សារ លន | ប្រធានការិយាល័យអប់រំ យុវជន និងកីឡាខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| ៤-លោក | គង់ ញ៉ឹល | ប្រធានការិយាល័យព័ត៌មានខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| ៥-លោក | ជា ម៉ិនអ៊ិត | ប្រធានការិយាល័យគណនេយ្យខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| ៦-លោកស្រី | ឈុំប សុខត្ថិឌី | ប្រធានការិយាល័យកិច្ចការនារីខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| ៧-លោក | ឡាយ ជ | ប្រធានការិយាល័យសាធារណៈការខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| ៨-លោក | សេង តារារិទ្ធ | ប្រធានការិយាល័យកសិកម្មខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| ៩-លោក | ពុំ អឿ | ប្រធានការិយាល័យបរិស្ថានខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| ១០-លោក | ឡុត ជុនអេង | ប្រធានការិយាល័យសង្គមកិច្ច អតីតយុទ្ធជន ខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| ១១-លោក | ខេង គឹមសាន | ប្រធានការិយាល័យឧស្សាហកម្ម-សិប្បកម្មខណ្ឌមានជ័យ រាជធានីភ្នំពេញ |

១២-លោក ឈុន យាខ ប្រធានការិយាល័យផែនការខណ្ឌមានជ័យ រាជធានីភ្នំពេញ
១៣-លោក ឌី សារឿន ប្រធានការិយាល័យអភិវឌ្ឍជនបទខណ្ឌមានជ័យ រាជធានីភ្នំពេញ
១៤-លោក ផូ ផារិទ្ធ ប្រធានការិយាល័យដែនដីនគរូបនីយកម្មខណ្ឌមានជ័យ
១៥-លោក ខាន់ ម៉ាន់ច្រាឡា ប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិខាងត្បូងខណ្ឌមានជ័យ
១៦-លោក ស៊ុំ ម៉ិនឈឿន ប្រធានការិយាល័យផ្នែកបុគ្គលិកខណ្ឌមានជ័យ រាជធានីភ្នំពេញ
១៧-លោក ជា សាយ ប្រធានក្រុមជំនួយការលោកអភិបាលខណ្ឌមានជ័យ
១៨-លោក ស៊ិន សាខន ប្រធានគណបក្សប្រជាជនសង្កាត់ច្បារអំពៅទី២ ខណ្ឌមានជ័យ
១៩-លោក ហ៊ិន ឡេង ប្រធានគណបក្សប្រជាជនសង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ
២០-លោក សរ ហាន មន្ត្រីទីស្នាក់ការគណបក្សប្រជាជនខណ្ឌមានជ័យ រាជធានីភ្នំពេញ
២១-លោក ស៊ឹម សាផុន មន្ត្រីទីស្នាក់ការគណបក្សប្រជាជនខណ្ឌមានជ័យ រាជធានីភ្នំពេញ
២២-លោក សំ ផុន ចៅសង្កាត់និរោធ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
២៣-លោក ពៅ ម្ហូត ចៅសង្កាត់ច្បារអំពៅទី ១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
២៤-លោក យ៉ិន ទុង ចៅសង្កាត់ច្បារអំពៅទី ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
២៥-លោក អ៊ឹម ទ៉ែនឌី ចៅសង្កាត់វាលទី១ សង្កាត់ព្រែកប្រា ខណ្ឌមានជ័យ រាជធានីភ្នំពេញ
២៦-លោក កែវ សារឿន ចៅសង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
២៧-លោក ជា សុខែ ចៅសង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ
២៨-លោក សួស សារិន ចៅសង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ
២៩-លោក សេង សាញ់ ចៅសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ខ- មេដាយស្ពាន់ការងារ

១-លោក កុយ ឈុល អធិការរងនគរបាលខណ្ឌមានជ័យ រាជធានីភ្នំពេញ
២-លោក មុំ ទ៉ៃ អធិការរងនគរបាលខណ្ឌមានជ័យ រាជធានីភ្នំពេញ
៣-លោក ជឹម ស៊ីថា អធិការរងនគរបាលខណ្ឌមានជ័យ រាជធានីភ្នំពេញ
៤-លោក ម៉ែន មោឧតិត្យ អធិការរងនគរបាលខណ្ឌមានជ័យ រាជធានីភ្នំពេញ
៥-លោក តេង ស៊ីណូ អធិការរងនគរបាលខណ្ឌមានជ័យ រាជធានីភ្នំពេញ
៦-លោក មាស សុខុម ប្រធានផ្នែកស្ថិតិអធិការដ្ឋាននគរបាលខណ្ឌមានជ័យ
៧-លោក មុំ ចាន់តារា មេបញ្ជាការរងកងរាជអាវុធហត្ថខណ្ឌមានជ័យ រាជធានីភ្នំពេញ
៨-លោក ហៀង ចន្ទី មេបញ្ជាការរងកងរាជអាវុធហត្ថខណ្ឌមានជ័យ រាជធានីភ្នំពេញ
៩-លោក លឹម ប្រុសើរ មេបញ្ជាការរងកងរាជអាវុធហត្ថខណ្ឌមានជ័យ រាជធានីភ្នំពេញ
១០-លោក ឡាក់ ស៊ីដេត មេបញ្ជាការរងកងរាជអាវុធហត្ថខណ្ឌមានជ័យ រាជធានីភ្នំពេញ
១១-លោកស្រី ខឹម វណ្ណនី នាយការិយាល័យសង្គមកិច្ចខណ្ឌមានជ័យ រាជធានីភ្នំពេញ
១២-លោក សន ណារ៉ាត់ នាយរងការិយាល័យសង្គមកិច្ចខណ្ឌមានជ័យ រាជធានីភ្នំពេញ
១៣-លោក ជិន លី អនុប្រធានការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈខណ្ឌមានជ័យ
១៤-លោកស្រី ម៉ុក ស៊ីណាត អនុប្រធានការិយាល័យកិច្ចការនារីខណ្ឌមានជ័យ

១៥-លោកស្រី ខាន់ កញ្ញា អនុប្រធានការិយាល័យសង្គមកិច្ច អតីតយុទ្ធជន ខណ្ឌមានជ័យ

១៦-លោក ឈាន ណារ៉ា ស្មៀនសង្កាត់ព្រែកប្រា ខណ្ឌមានជ័យ រាជធានីភ្នំពេញ

**គ. មេដាយសេវាការងារ**

១-លោក ចិន ធីរ៉ូ សមាជិកក្រុមប្រឹក្សាសង្កាត់ព្រែកប្រា ខណ្ឌមានជ័យ

២-លោក ម៉ី សំអុល សមាជិកក្រុមប្រឹក្សាសង្កាត់ព្រែកប្រា ខណ្ឌមានជ័យ

៣-លោក ឈុន ណុត សមាជិកក្រុមប្រឹក្សាសង្កាត់ព្រែកប្រា ខណ្ឌមានជ័យ

៤-លោក មូណាំង អ៊ីចន សមាជិកក្រុមប្រឹក្សាសង្កាត់ព្រែកប្រា ខណ្ឌមានជ័យ

៥-លោក ទ្រាំ ចន មេភូមិព្រះពន្លា សង្កាត់ព្រែកប្រា ខណ្ឌមានជ័យ រាជធានីភ្នំពេញ

៦-លោក ឈឹម សារិ មេភូមិជ្រោយបាសាក់ សង្កាត់ព្រែកប្រា ខណ្ឌមានជ័យ

៧-លោក ម៉ើ យូ មេភូមិព្រែកតាពៅ សង្កាត់ព្រែកប្រា ខណ្ឌមានជ័យ

៨-លោក សួន សាធ មេភូមិអូរអណ្តូង សង្កាត់ព្រែកប្រា ខណ្ឌមានជ័យ

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ២ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និងមាត្រា ២
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧១៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសការងារ** តាមលំដាប់ថ្នាក់ ជូនអស់លោកមន្ត្រីរាជការស៊ីវិលចំនួន ០៩ រូប ដែលមានស្នាដៃឆ្នើមក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិបានល្អ ដូចមានរាយនាមខាងក្រោម :

| | | |
|---|---|---|
| ១-លោក | **ទាំង ជាវ៉ាង** | ប្រធានការិយាល័យចំណូលសាលាខេត្តបន្ទាយមានជ័យ |
| ២-លោក | **សោ ឆេងហុង** | អភិបាលរងស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ |
| ៣-លោក | **ស៊ីទ សារួន** | អនុប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបន្ទាយមានជ័យ |
| ៤-លោក | **អ៊ុន សីវុទ្ធ** | អនុប្រធានការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្ត |
| ៥-លោក | **ចាច់ ហាន់** | ប្រធានការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្ត |
| ៦-លោក | **ខៀម សេរី** | អនុប្រធានផ្នែក នៃស្នងការដ្ឋាននគរបាលខេត្ត |
| ៧-លោក | **យិម យឿន** | ប្រធានការិយាល័យសាលាស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ |
| ៨-លោក | **ឆៀង ឡុង** | សមាជិកក្រុមប្រឹក្សាឃុំទានកាំ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ |
| ៩-លោក | **គីម ទិន** | អនុប្រធានការិយាល័យសាលាស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ |

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៩៦ សហវ.ប្រក.ពន្ធ

# ប្រកាស
## ស្តីពី
## ការបែងចែកប្រាក់រង្វាន់ពីការត្រួតពិនិត្យពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញក្រឹត្យលេខ ២៤/ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ
- បានឃើញអនុក្រឹត្យលេខ ០៨/អនក្រ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩១ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ
- បានឃើញប្រកាសលេខ ០០៤ ប្រក/សហវ/ពដ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០០១ ស្តីពីការផ្តល់រង្វាន់ជូនអង្គភាពពន្ធដារ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
... Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញប្រកាសលេខ ២៨៧ សហវ/ពជ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៣ ស្តីពីការបែងចែកប្រាក់រង្វាន់របស់អង្គភាពពន្ធដារ
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៨ ។

**សំរេច :**

**ប្រការ ១ :** ក្នុងរយៈពេលត្រួតពិនិត្យជារៀងរាល់ឆ្នាំ ប្រាក់ផាកពិន័យលើពន្ធមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដែលទទួលបានក្នុងការចូលរួមកិច្ចប្រតិបត្តិការត្រួតពិនិត្យ ដោយមានសហការរវាងមន្ត្រីពន្ធដារ និងមន្ត្រីមានសមត្ថកិច្ច ត្រូវអនុញ្ញាតឱ្យបែងចែកជាប្រាក់រង្វាន់តាមសមាមាត្រ ដូចតទៅ :

១- ៥០% (ហាសិបភាគរយ) ត្រូវបង់ចូលថវិការដ្ឋ ។

២- ៥០% (ហាសិបភាគរយ) ត្រូវបានអនុញ្ញាតឱ្យបែងចែកជាប្រាក់រង្វាន់ ដូចតទៅ :

- ១៥% (ដប់ប្រាំភាគរយ) បង់ចូលអគ្គនាយកដ្ឋានពន្ធដារ
- ៣៥% (សាមសិបប្រាំភាគរយ) សំរាប់បែងចែកដូចខាងក្រោម : (១០០% នៃ ៣៥%)
  - \+ ៦០% នៃប្រាក់រង្វាន់ សំរាប់ចែកជូនសមាជិកនៃក្រុមប្រតិបត្តិការត្រួតពិនិត្យ ។
  - \+ ២០% នៃប្រាក់រង្វាន់ សំរាប់បេឡាសមូហភាពរបស់សាខាពន្ធដារខេត្ត ឬសាខាពន្ធដារខណ្ឌ នៃរាជធានីភ្នំពេញ ។
  - \+ ១០% នៃប្រាក់រង្វាន់ សំរាប់បេឡាសមូហភាពរបស់សាលាខេត្ត ឬរាជធានីភ្នំពេញ ។
  - \+ ១០% នៃប្រាក់រង្វាន់ សំរាប់បេឡាសមូហភាពរបស់សាលាខណ្ឌ-ស្រុក-ក្រុង ។

**ប្រការ ២ :** អនុញ្ញាតឱ្យសាខាពន្ធដារខេត្ត ឬសាខាពន្ធដារខណ្ឌ នៃរាជធានីភ្នំពេញ ដកប្រាក់រង្វាន់ពីការផាកពិន័យពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំនីមួយៗភ្លាម សំរាប់បែងចែកជូនសមាជិកក្រុមត្រួតពិនិត្យ និងអង្គភាពតាមសមាមាត្រដូចបានចែងក្នុងប្រការ១ខាងលើ ហើយត្រូវធ្វើរបាយការណ៍បូកសរុបពីស្ថានភាពចំណូល និងចំណាយបេឡាប្រាក់ផាកពិន័យនេះជូនអគ្គនាយកដ្ឋានពន្ធដារ ដើម្បីត្រួតពិនិត្យ និងសំរាប់ទូទាត់ជាក្រោយ ដូចមានគំរូឧបសម្ព័ន្ធភ្ជាប់មកជាមួយ ។

**ប្រការ ៣ :** ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០០៨

**គាត ឈន់**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជារបាយការណ៍"
- គ្រប់ក្រសួង-ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត រាជធានីភ្នំពេញ-ក្រុង-ខណ្ឌ-ស្រុក "ដើម្បីជូនជ្រាបជាពត៏មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួង "ដើម្បីមុខការ"
- គ្រប់សាខាពន្ធដារខេត្ត សាខាពន្ធដារខណ្ឌ នៃរាជធានីភ្នំពេញ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខៈ..២១១.....សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី២៧ខែកុម្ភៈ ឆ្នាំ ២០០៩

# ប្រកាស
## ស្តីពី
## ការបង្កើត និងកិច្ចដំណើរការអង្គភាពគ្រប់គ្រងតម្លៃចម្លងការនៃទំនិញនាំចូល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងឋានៈ ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១២៦៣ សហវ.ប្រក ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់បណ្តាការិយាល័យនៃនាយកដ្ឋានផែនការបច្ចេកទេស និងកិច្ចការអន្តរជាតិ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- បានឃើញប្រកាសលេខ ៣៨៧ សហវ.គរ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកំណត់តម្លៃគិតពន្ធគយលើទំនិញនាំចូល
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

បង្កើតអង្គភាពគ្រប់គ្រងតម្លៃចម្លងការនៃទំនិញនាំចូល ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដែលដឹកនាំដោយមន្ត្រីរាជការគយនិងរដ្ឋាករដូចតទៅ ៖

| | | |
|---|---|---|
| ១- លោក **គុណ ញឹម** | អគ្គនាយករងគយនិងរដ្ឋាករកម្ពុជា | ប្រធាន |
| ២- លោក **ប៉ែន សំអាត** | ប្រធានលេខាធិការដ្ឋាន និងជាប្រធាននាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ | អនុប្រធាន |
| ៣- លោក **នួន ច័ន្ទរិទ្ធ** | ប្រធាននាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- លោក **ម៉ុរ ម៉ុនណារ៉ា** | ជំនួយការនាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ | សមាជិក |
| ៥- លោក **សុខ សុទិន្នា** | អនុប្រធានទទួលបន្ទុករួមការិយាល័យបច្ចេកទេសគយ | សមាជិក |
| ៦- លោក **រស់ ដារ៉ា** | អនុប្រធានទទួលបន្ទុករួមការិយាល័យផែនការ គោលនយោបាយ | សមាជិក |
| ៧- លោក **សម់ ស៊ីណាវិទ្យ** | ជំនួយការនាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ | សមាជិក |
| ៨- លោកស្រី **ហេង សំអូន** | ជំនួយការនាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ | សមាជិក |
| ៩- លោក **ដួង បូលីន** | ជំនួយការការិយាល័យលេខាធិការ និងជំនួយការ | សមាជិក |

**ប្រការ ២.-**

អង្គភាពគ្រប់គ្រងតម្លៃចម្លងការនៃទំនិញនាំចូល ត្រូវបានបែងចែកជា ៣ ក្រុមការងារ ដែលមានការកិច្ចគ្រប់គ្រងការវិវត្តតម្លៃចម្លងការនៃទំនិញនាំចូល ដូចតទៅ ៖

ក្រុមការងារទី ១ ៖ ទទួលបន្ទុកគ្រប់គ្រងតម្លៃចម្លងការនៃទំនិញនាំចូល ចាប់ពីជំពូក ១ ដល់ជំពូក ៦៧ នៃតារាងពន្ធគយកម្ពុជាជាធរមាន ដែលមានសមាសភាពចូលរួមពីមន្ត្រីរាជការគយនិងរដ្ឋាករ ដូចខាងក្រោម ៖

| | |
|---|---|
| ១- លោក **រស់ ដារ៉ា** | ប្រធាន |
| ២- លោកស្រី **ហេង សំអូន** | អនុប្រធាន |
| ៣- លោក **ដួង បូលីន** | អនុប្រធាន |
| ៤- លោក **តាំ ច័ន្ទកុសល** | សមាជិក |
| ៥- លោក **កែវ ស៊ីន** | សមាជិក |
| ៦- លោក **ម៉ាក់ វិសាល** | សមាជិក |

៧- លោក **ណាំ សុណាង** សមាជិក

៨- លោក **ឯម វុទ្ធី** សមាជិក

៩- លោកស្រី **ជាស័ក្តិ ថាវី** សមាជិក

ក្រុមការងារទី ២ ៖ ទទួលបន្ទុកគ្រប់គ្រងតម្លៃចម្លងការនៃទំនិញនាំចូល ចាប់ពីជំពូក ៦៩ ដល់ជំពូក ៨៤ នៃតារាងពន្ធគយកម្ពុជាជាធរមាន ដែលមានសមាសភាពចូលរួមពីមន្ត្រីរាជការគយនិងរដ្ឋាករ ដូចខាងក្រោម ៖

១- លោក **សុខ សុទិន្យា** ប្រធាន

២- លោក **ម៉ុក ហួត** អនុប្រធាន

៣- លោក **ប៉ោ សួន** អនុប្រធាន

៤- លោក **អ៊ឹង ដារ៉ែង** សមាជិក

៥- លោកស្រី **រ៉ែន ច័ន្ទសទ្ធារត** សមាជិក

៦- លោក **ឆួច លីដែល** សមាជិក

៧- លោក **លន ចិត្រា** សមាជិក

៨- លោកស្រី **គីម ណាលី** សមាជិក

៩- លោក **កោះ និច្ច** សមាជិក

ក្រុមការងារទី ៣៖ ទទួលបន្ទុកគ្រប់គ្រងតម្លៃចម្លងការនៃទំនិញនាំចូល ចាប់ពីជំពូក ៨៥ ដល់ជំពូក ៩៨ នៃតារាងពន្ធគយកម្ពុជាជាធរមាន ដែលមានសមាសភាពចូលរួមពីមន្ត្រីរាជការគយនិងរដ្ឋាករ ដូចខាងក្រោម ៖

១- លោក **ម៉ិរ ម៉ិនណារ៉ា** ប្រធាន

២- លោក **សង់ ស៊ីណាទិន្យ** អនុប្រធាន

៣- លោក **ស្រេង សំណាង** អនុប្រធាន

៤- លោក **អ៊ីម តាំងតា** សមាជិក

៥- លោក **ជា សំណាង** សមាជិក

៦- លោក **លឹម កេង** សមាជិក

៧- លោក **ស៊ីថុន ស៊ីថានា** សមាជិក

៨- លោក **សាយ សុផា** សមាជិក

៩- លោក **យ៉ឹក យូ** សមាជិក

**ប្រការ ៣.-**

អង្គភាពគ្រប់គ្រងតម្លៃចម្លងការនៃទំនិញនាំចូលនេះ មានតួនាទី និងភារកិច្ចដូចតទៅ ៖

- គ្រប់គ្រងការងារស្រាវជ្រាវ និងលើកសំណើគោលនយោបាយតម្លៃគិតពន្ធគយ ស្របតាមបញ្ញត្តិច្បាប់ជាធរមាន ឈានទៅធានាឲ្យបាននូវអនុលោមភាពរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងការអនុវត្តឲ្យមានប្រសិទ្ធភាពនូវកិច្ចព្រមព្រៀងស្តីពីការអនុវត្តមាត្រា ៧ នៃកិច្ចព្រមព្រៀងទូទៅស្តីពីតារាងពន្ធគយ និងពាណិជ្ជកម្ម (GATT) ឆ្នាំ ១៩៩៤ របស់អង្គការពាណិជ្ជកម្មពិភពលោក (WTO)
- លើកឡើងនូវផែនការសកម្មភាព ការកំណត់អាទិភាព និងវិសាលភាពនៃការអនុវត្តតាមវាក្យខ័ណ្ឌ ១ នៃប្រការនេះ រួមបញ្ចូលទាំងការងារវិមជ្ឈការ ប្រតិបត្តិការកំណត់ ឬផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ ឲ្យបានស្របតាមបញ្ញត្តិប្រកាសលេខ ៣៨៧ សហវ.គរ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកំណត់តម្លៃគិតពន្ធគយលើទំនិញនាំចូល និងតាមបទប្បញ្ញត្តិជាធរមានផ្សេងទៀត
- សម្របសម្រួលជាមួយនាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ និងនាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដើម្បីធានាឲ្យបាននូវភាពស៊ីចង្វាក់នៃការកសាងគោលនយោបាយ និងអនុលោមភាពលើទិដ្ឋភាពច្បាប់ និងបច្ចេកទេស
- សម្របសម្រួលជាមួយផ្នែកឯកជនពាក់ព័ន្ធក្នុងភាពជាដៃគូ ធានាឲ្យបាននូវការចូលរួមតាមរូបភាពផ្សេងៗក្នុងការពិគ្រោះយោបល់ ក្នុងករណីយល់ថាចាំបាច់ ដើម្បីកសាងមូលដ្ឋានទិន្នន័យតម្លៃចម្លងការនៃទំនិញ សម្រាប់ជាមូលដ្ឋានសំខាន់បំផុតលើការកំណត់តម្លៃគិតពន្ធគយ ។ ការងារនេះអាចដំណើរការតាមរយៈយន្តការ "ភាពជាដៃគូគយ-ផ្នែកឯកជន" Customs-Private Sector Partnership – CPSP តាមការកំណត់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- បំពេញការកិច្ចផ្សេងទៀត ក្នុងគោលបំណងធានានូវចីរភាពនៃការកំណត់តម្លៃគិតពន្ធគយតាមការកំណត់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ។

**ប្រការ ៤.-**

ក្រុមការងារស្រាវជ្រាវតម្លៃចម្លងការនៃទំនិញនាំចូល ដូចមានចែងក្នុងបញ្ញត្តិប្រការ ២ នៃប្រកាសនេះ មានភារកិច្ចដូចតទៅ ៖

- ស្រាវជ្រាវ តាមដានជាប្រចាំនូវការវិវត្តតម្លៃចម្លងការនៃទំនិញនាំចូល ពីពេលមួយទៅពេលមួយ ដោយអនុលោមតាមបញ្ញត្តិប្រការ ៩ នៃប្រកាសលេខ ៣៨៧ សហវ.គរ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកំណត់តម្លៃគិតពន្ធគយលើទំនិញនាំចូល ព្រមទាំងបញ្ញត្តិមាត្រា ២១ និង ២២ នៃច្បាប់ស្តីពីគយ ដោយប្រើប្រាស់ទិន្នន័យមានស្រាប់ ក្នុងរបាយការណ៍ជាក់ស្តែងនានា ទិន្នន័យស្រង់ចេញពីកិច្ចបញ្ជីការគណនេយ្យពាក់ព័ន្ធនឹងតម្លៃទំនិញរបស់បុគ្គលផ្សេងៗ និងពីប្រភពទិន្នន័យផ្សេងទៀត សម្រាប់ជាមូលដ្ឋានពិចារណាបន្ថែម ដូចជាតម្លៃទំនិញលើគេហទំព័រ ប្រព័ន្ធទិន្នន័យតម្លៃគិតពន្ធគយនានាដែលអាចរកបាន

ធ្វើរបាយការណ៍ប្រចាំខែ ពីលទ្ធផលការងាររបស់ខ្លួន ជូនអង្គភាពគ្រប់គ្រងតម្លៃចម្លងការនៃទំនិញនាំចូល ដូចមានចែងក្នុងបញ្ញត្តិប្រការ ១ នៃប្រកាសនេះ

កសាង និងកែសម្រួលរៀងរាល់ដំណាច់ខែនីមួយៗ នូវតារាងតម្លៃចម្លងការនៃទំនិញសម្រាប់ពិចារណា (Transactional Value List for Consideration) លើមុខទំនិញដែលស្ថិតក្នុងមុខសញ្ញាគ្រប់គ្រងរបស់ខ្លួន ដូចមានចែងក្នុងបញ្ញត្តិប្រការ ២ នៃប្រកាសនេះ សម្រាប់ជាមូលដ្ឋានក្នុងការពិនិត្យផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ ដែលបានប្រកាសដោយធុរជន ឲ្យបានឆាប់រហ័ស និងស្របតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ព្រមទាំងជានាឲ្យបាននូវប្រសិទ្ធភាពនៃការប្រមូលចំណូលពន្ធ និងអាករគយ

- អនុវត្តការកិច្ចផ្សេងទៀតតាមការកំណត់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ។

**ប្រការ ៥.-**

មន្ត្រីរាជការគយនិងរដ្ឋាករដូចមានរាយនាមក្នុងបញ្ញត្តិប្រការ ១ និងប្រការ ២ នៃប្រកាសនេះ ត្រូវបំពេញការកិច្ចតាមបញ្ញត្តិនៃប្រកាសនេះបន្ថែមលើមុខងារបច្ចុប្បន្ន ។

**ប្រការ ៦.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួន ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**<u>ចម្លងជូន៖</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- ដូចប្រការ ៦ "ដើម្បីអនុវត្ត"
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីសហការផ្សព្វផ្សាយ"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៧១២ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ
## សំរាប់ឆ្នាំ២០០៩

### ឧបនាយករដ្ឋមន្ត្រី
### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៩
- បានឃើញក្រឹត្យលេខ ២៤/ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៨១ ដែលប្រកាសឱ្យប្រើច្បាប់ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៨១ ស្តីពីការបង្កើតពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ

- បានឃើញអនុក្រឹត្យលេខ ០៨/អនក្រ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩១ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៩

**សំរេច :**

**ប្រការ១.-** ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ២០០៩ ត្រូវប្រមូលចាប់ពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០០៩ រហូតដល់ថ្ងៃទី ៣១ ខែ មិថុនា ឆ្នាំ២០០៩ ។

**ប្រការ២.-** ដើម្បីបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៩ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវបំពេញលិខិតប្រកាសចំនួន ០២ សន្លឹក តាមគំរូឯកភាពរបស់អគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងបង្ហាញ និងប្រគល់ជូនមន្ត្រីដែលមានសមត្ថកិច្ចនូវបង្កាន់ដៃបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ២០០៨ ដើម្បីជាភស្តុតាងបញ្ជាក់ថា មធ្យោបាយដឹកជញ្ជូន និងយានជំនិះនោះបានបង់ពន្ធសំរាប់ឆ្នាំ២០០៨ រួចហើយ លើកលែងតែទោចក្រយានយន្តទេ ដែលមិនចាំបាច់បំពេញលិខិតប្រកាស ។

**ប្រការ៣.-** ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទណា ពុំមានបង្កាន់ដៃបញ្ជាក់ថាបានបង់ពន្ធឆ្នាំ២០០៨ ទេនោះ ត្រូវបង់ប្រាក់ពន្ធសំរាប់ឆ្នាំ២០០៨ និងត្រូវបង់ប្រាក់ពិន័យដែលមានចំនួនស្មើនឹងប្រាក់ពន្ធ ទើបអនុញ្ញាតអោយបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៩ ។

**ប្រការ៤.-** ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទណាដែលបាត់បង្កាន់ដៃបង់ពន្ធសំរាប់ឆ្នាំ២០០៨ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនោះ ត្រូវមានលិខិតបញ្ជាក់ថា បានបង់ពន្ធសំរាប់ឆ្នាំ២០០៨ រួចហើយ ដែលចេញដោយប្រធានសាខាពន្ធដារខេត្ត ឬខណ្ឌនៃរាជធានីភ្នំពេញ នៃទីកន្លែងដែលបានបង់ពន្ធសំរាប់ឆ្នាំ២០០៨ ។

**ប្រការ៥.-** ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវកំណត់លើគ្រប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះ ដោយមិនគិតថាជារបស់រដ្ឋ ឬឯកជនឡើយ ទៅតាមប្រភេទនីមួយៗ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធ I និង II ភ្ជាប់ជាមួយនឹងប្រកាសនេះ ។

**ប្រការ៦.-** ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវបានលើកលែងចំពោះ :

- រថយន្តគិលានសង្គ្រោះ រថយន្តពន្លត់អគ្គីភ័យរបស់រដ្ឋ ។
- មធ្យោបាយដឹកជញ្ជូន និងយានជំនិះ ជាកម្មសិទ្ធិរបស់កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ ដែលបំរើឱ្យការងារសំរាប់កិច្ចការពារប្រទេស សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ។
- មធ្យោបាយដឹកជញ្ជូន និងយានជំនិះ របស់ស្ថានទូត ឬកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ។

**ប្រការ៧.-** ក្រោយពេលបង់ពន្ធបានត្រឹមត្រូវរួចហើយ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនីមួយៗ ត្រូវបានទទួលបង្កាន់ដៃបង់ពន្ធមួយសន្លឹក និងប័ណ្ណសំគាល់មួយសន្លឹក សំរាប់បិទភ្ជាប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនីមួយៗនោះ ។

បង្កាន់ដៃបង់ពន្ធនេះមានបិទក្រដាសពណ៌ទឹកប្រាក់ រចនាដោយអក្សរក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរូបហង្សត្រួតពីលើ និងមានពន្លឺប្រាំពីរពណ៌ ដោយឡែកសំរាប់បង្កាន់ដៃបង់ពន្ធលើរថយន្ត មានបន្ថែមអក្សរ សហវ និងមានសរសេរចំនួនប្រាក់ពន្ធ ៨០,០០០រៀល ១០០,០០០រៀល ១៥០,០០០រៀល ១៨០,០០០រៀល ២០០,០០០រៀល ២៥០,០០០រៀល ៤៥០,០០០រៀល ៦០០,០០០រៀល ៧៥០,០០០រៀល ៨០០,០០០រៀល ១,០០០,០០០រៀល នៅពីក្រោម ។ បង្កាន់ដៃបង់ពន្ធនេះត្រូវថែរក្សាកុំអោយបាត់បង់ និងត្រូវយកជាប់ជាមួយសំរាប់ទុកបង្ហាញមន្ត្រីត្រួតពិនិត្យដែលមានសមត្ថកិច្ច និងទុកជាឯកសារសំរាប់បង់ពន្ធឆ្នាំ២០១០ ។

**ប្រការ៨.-** សំរាប់ឆ្នាំ២០០៩ ប័ណ្ណសំគាល់ដែលត្រូវបិទភ្ជាប់នឹងមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ មានរូបភាព និងលក្ខណៈសំគាល់ដូចខាងក្រោម :

**១.ប័ណ្ណរាងឆកោណ :**

នៅខាងលើបំផុតនៃប័ណ្ណមានអក្សរ "ព្រះរាជាណាចក្រកម្ពុជា" ។ ខាងក្រោមបំផុតមានអក្សរ "ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ" ។ នៅកណ្តាលមានលេខ "២០០៩" សញ្ញារូបហង្ស និងមានអក្សរ "ប័ណ្ណបង់ពន្ធរថយន្ត" កាត់ពាក់កណ្តាលសញ្ញារូបហង្ស និងត្រួតលើលេខ "២០០៩" ។ ខាងក្រោម "ប័ណ្ណបង់ពន្ធរថយន្ត" មានសរសេរចំនួនប្រាក់ពន្ធ ។ ខាងក្រោមចំនួនប្រាក់ពន្ធ មានសរសេរលេខរៀងនៃប័ណ្ណនីមួយៗ ។ នៅផ្នែកខាងមុខប័ណ្ណមានបិទក្រដាសពណ៌ទឹកប្រាក់ រចនាដោយអក្សរក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរូបហង្សត្រួតពីលើ និងមានពន្លឺប្រាំពីរពណ៌ ដោយឡែកសំរាប់រថយន្តមានបន្ថែមអក្សរ សហវ និងមានសរសេរចំនួនប្រាក់ពន្ធពី ៨០,០០០រៀល ដល់ ១,០០០,០០០រៀល ។

ប័ណ្ណរាងឆកោណនេះ មាន**១២**ពណ៌គឺ :

- **ប័ណ្ណពណ៌ទឹកប៊ិច ប្រើសំរាប់ :**
  + ត្រាក់ទ័រមានកម្លាំង ៣៥ សេះ
  + ត្រាក់ទ័រមានកម្លាំង ៦៥ សេះ
  + ត្រាក់ទ័រមានកម្លាំង ៨២ សេះ
- **ប័ណ្ណពណ៌ខៀវខ្ចី ប្រើសំរាប់ :**
  + រថយន្តទេសចរណ៍កម្លាំងដល់ ៩ សេះ គិតពីឆ្នាំផលិតលើសពី ៥ឆ្នាំ
- **ប័ណ្ណពណ៌បៃតង ប្រើសំរាប់ :**
  + រថយន្តទេសចរណ៍កម្លាំង ៩ សេះ គិតពីឆ្នាំផលិតដល់ ៥ឆ្នាំ
